ពេលដកដង្ហើមធូរស្រាលបានបន្តិច រួចរាល់ពីការសូត្រហើយ គ្រូភ័ក្ត្រ មិនបានទុកពេលឱ្យពួកគេ បានសាកសួរអ្វីទេ គាត់រវល់ទាញកូនប្រុសទៅម្ខាងហើយខ្សឹបខ្សៀវចុះឡើង។

វណ្ណដូឃើញគ្រូភាចាប់ផ្តើមរត់ត្របាញ់ជើងចេញទៅដោយមិនបាននិយាយអ្វីមួយម៉ាត់ណា។ ពេលដែលកូនប្រុសរត់ចេញទៅបាត់ទំនងជាត្រូវរកអ្វីសំខាន់មកឱ្យឪពុករបស់ខ្លួនតាមបទបញ្ជា គ្រូភ័ក្ត្រនេះបែរមករកសីហាវិញម្តង។

ដោយសម្លក់សីហានិងសម្លឹងពីលើដល់ក្រោមចុះឡើង ឡើងចុះ សីហាដែលមិនមាត់មិនកតាំងពីភ្នំពេញមកដល់ពេលនេះ គេនៅតែមិនសម្លឹងអ្នកណាទាំងអស់ ប្រឹងតែជ្រប់មុខសម្លឹងក្តារនាប។

ឃើញគ្រូភ័ក្ត្រតាមពិនិត្យ ម្តាយសីហាបានព្យាយាមកេះកូនប្រុសថា៖

«សីហាឆាប់ ជម្រាបសួរលោកគ្រូទៅកូន!»

សីហាលើកដៃប្រណម្យ។ ចំណែកលោកគ្រូបាននិយាយឡើងថា៖

«សីហា! អន្ទិតសីហាឯងមានការអ្វីនៅក្នុងខ្លួន?»

«ខ្ញុំគ្មានអ្វីទាំងអស់លោកគ្រូ!»

អាចារ្យងក់ក្បាល៖

«ល្អហើយ! បើគ្មានអ្វីទាំងអស់ ក៏ចូលមកបាន!»

សីហាមិនកម្រើកទេ ទោះម្តាយក៏ខំរុញកាយគេម្តងហើយម្តងទៀត ក៏សីហាមិនកម្រើក។

ម្តាយជម្នះរុញតឿនកូនម្តងទៀត សីហាក៏រេខ្លួនតិចតួចចូលទៅក្បែរលោកគ្រូ។ លោកគ្រូភ័ក្ត្រចាប់ផ្តើមដាក់ខ្សែអង្កាំនៅចំពោះមុខគេ ខណៈសីហាញ័រខ្លួនតែម្តង។

«ចាប់កូនឱ្យជាប់ ហើយនៅឱ្យស្ងៀម»

លោកគ្រូបង្គាប់ម៉ែសីហា និងបងជីដូនមួយគេ ស្ទុះចូលជួយទប់ នៅតែហាក់មិនជាប់ព្រោះសីហាញ័រខ្លាំងឡើងៗបម្រះរកតែក្រោក។

ខណៈនេះអ្នកណាមិនភ័យ? ភ្នែកម្តាយសីហាចេញរបៀបសួរជាសម្ងាត់ទៅកាន់លោកគ្រូថា តើមានរឿងអ្វីកើតឡើងចំពោះកូនរបស់គាត់ លោកគ្រូភ័ក្ត្រមិនមាត់នោះទេ គាត់លើកដៃ

ម្ខាងប្រណម ដៃម្ខាងទៀតចាប់ផ្ដើមរលាស់អង្កាំចុះឡើងនៅចំពោះមុខរបស់សីហា។ លើកនេះមិនត្រឹមសីហាវេផ្លូវរកគេចថែមទាំងស្រែករោទ៍។

ម្ដាយគេនិងបងគេផងហាក់ទប់មិនចង់បាននឹងកម្លាំងបម្រះរបស់សីហា វណ្ណដូក៏ទម្លាក់សាក់ដូចោលហើយរត់ទៅជួយចាប់ម្នាក់ទៀត។

ស្រាប់តែគ្រូភ័ក្ត្រឈប់មាត់ គាត់បញ្ជាទៅអ៊ំកែមថាៈ

«ចាប់បងកែម! ជួយចាប់! ម្ដាយនេះថយចេញ»

ម្ដាយសីហា ដោយទឹកមុខព្រួយភ័យបានថយមកក្រោយតាមបញ្ជាអ្នកអាចារ្យ ទុកកូនប្រុសរបស់គាត់នៅក្នុងការសន្ធប់របស់ប្រុសទាំងបី។

ពេលនោះហើយលោកគ្រូចាប់ផ្ដើមដាក់ខ្សែអង្កាំនៅជុំវិញសក់របស់គេ ធ្វើឲ្យសីហាស្រែកកញ្ច្រៀវ លាន់រំពងពេញសាលាមួយនេះ។

ម្ដាយគេជូតទឹកភ្នែក។

ខណៈដែលសីហាកាន់តែរោទ៍ដូចជ្រូកត្រូវទឹកក្ដៅ លោកគ្រូកាន់តែសូត្រញាប់ឡើងៗៗ។ គាត់កាន់តែសូត្រ សីហាម្ចាស់ខ្លួនក៏កាន់តែរញ្ជួយរើរូច សឹងតែកម្លាំងដំរីសារដែលគ្មានអ្នកណាចាប់ជាប់ទេ។

ស្មានថាបន្តិចទៀតគ្រប់គ្នាទប់នឹងសីហាលែងជាប់ទៅហើយ ព្រោះហត់ខ្លាំង បងជីដូនមួយរបស់គេក៏ចាប់ផ្ដើមងើបមុខដែលបែកញើសជោកសង្កត់ខ្លួនប្អូនពីលើពេញទំហឹងនិងសម្លឹងទៅលោកគ្រូក្នុងពេលជាមួយគ្នា ដូចជាចង់សួរថាតើពេលណាចប់ពិធី ព្រោះសីហាកញ្ជ្រោលខ្លាំងឡើងៗ។

ភ្លាមនោះលោកគ្រូចាប់ផ្ដើមដក យកអង្កាំមកវិញ ហើយវាយផ្ទូងទៅលើក្បាលរបស់សីហា ធ្វើឲ្យសីហាស្រែកវ៉ាស ស្ទុះក្រោកចេញពីសាលាជំនុំ ប៉ុន្តែតាកែមដូចជាបានដឹងរឿងមុនទៅហើយក៏ស្ទុះទៅបិទទ្វារបានមុន ធ្វើឲ្យសីហាដែលរើរបូតរាល់ការចាប់ ប្រឹងរត់មកដល់មាត់ទ្វារក៏ទន់ជង្គង់ដួលត្មោលទៅលើកម្រាលឫស្សីក្រាំង។

ម្ដាយសីហាភ័យស្លេកស្លាំងក្រោកមិនរួច អង្គុយពោបទៅលើក្ដាររនាបយំរហាមសម្លឹងកូនប្រុស។

លោកគ្រូភ័ក្ត្រក៏បានបង្គាប់ឲ្យប្រុសៗជួយគ្រាហ៍យកសីហាមកដេកសណ្ដូកដៃជើងទទឹងអាសនៈ។ ពេលនេះគាត់បានអុជធូបមួយសំណុំថ្មីឡើង ដែលមានប្រមាណពីដប់ប្រាំទៅម្ភៃដើមយ៉ាងតិច។

គាត់អង្គុយនៅចុងជើងសីហាហើយសូត្រធម៌ រួចក្រោកមកក្រឡឹងជើងធូបនៅជុំវិញខ្លួនរបស់សីហាដែលគិតពីបន្តសន្លប់មិនដឹងអ្វី។

ការនេះធ្វើឲ្យម្ដាយជូតទឹកភ្នែកយ៉ាងញាប់។

មិនយូរប៉ុន្មានស្នូរម៉ូតូនៅខាងក្រោមកុដិ។

វណ្ណដូក្រោកទៅទាញសាក់កាដូដែលបានបោះចោលអម្បាញ់មិញរៀបរយទៅម្ខាងហើយសម្លឹងទៅក្រោមឃើញ គ្រូនភាត្រូវបានដឹកមកដល់ដោយក្មេងជំទង់ម្នាក់។ ដៃគ្រូនេះ មានកាន់មាន់រស់ពីរក្បាលមកផង។

ជាមួយនឹងអីវ៉ាន់នៅខាងមុខម៉ូតូសំពីងសំពោង វណ្ណដូទាយដឹងថា ភាគច្រើនសុទ្ធតែជាគ្រឿងសក្ការបូជាសម្រាប់រឿងរបស់សីហាហើយ។

«កែមចុះទៅរៀបចំពិធីឲ្យលឿនមុនពេលថ្ងៃលិច!»

នេះគឺជាបញ្ជារបស់គ្រូភ័ក្ត្រ ដូច្នេះហើយអ៊ំកែមបានស្រវាដើរចុះតុកៗតាមជណ្ដើរកុដិទៅទទួលយកឥវ៉ាន់ពីកូនប្រុសរបស់គ្រូភ័ក្ត្រ។

ពួកគេលើកគ្រែឫស្សីចេញពីក្រោមកុដិ វណ្ណដូក៏ចុះទៅជួយលើកជាមួយពួកគេដែរ។

មិនយូរប៉ុន្មានក្មេងជំទង់ដែលបើកម៉ូតូចេញទៅមុននេះ បានវិលមកវិញមានដឹកមនុស្សចាស់ពីរនាក់ទៀតមកដែរ។ អ៊ំទាំងពីរម្នាក់វ័យប្រហែលចិតប្លាយម្នាក់ទៀតខ្ទង់ហា។

ក្នុងរូបរាងស្គមស្គាំងសម្បុរស្បែកខ្មៅប៉ុន្តែមានទឹកមុខរួសរាយរាក់ទាក់ ពួកគាត់ទំនងជាអាចារ្យដែរ បើមើលតាមរបៀបស្លៀកពាក់។

លោកតាម្នាក់កាន់ផ្កាមកហើយអ៊ំម្នាក់ទៀត នោះបានកាន់ចេកពីស្និតមក។

ឥឡូវនេះវណ្ណដូរថយមកឈរមើលសំណែនជាច្រើនដែលត្រូវបានគេរៀបចំក្រាលពីលើពាសពេញគ្រែឫស្សីដ៏ធំទំហំប្រហែលជាមួយម៉ែត្រប្រាំបី។

មើលទៅដូចជាពួកគេកំពុងតែរៀបចំលក់គ្រឿងបន្លែបង្ការនិងផលានុផលអ្នកស្រុកដូច្នោះដែរប៉ុន្តែតាមពិតទៅពួកគេសែនព្រេនឲ្យសីហាប្រាកដណាស់។

មាន់រស់ទាំងពីរត្រូវបានគេចងទាំងរស់នៅនឹងមុខជើងគ្រែទាំងសងខាង។

នៅលើចង្អេរមួយ វណ្ណដូឃើញតាកែមចាក់រាយ គ្រាប់សណ្តែកដីលាយឡំជាមួយនឹងពំនូកស្រូវមិនទាន់បុក។ ចំកណ្តាលចង្អេរមានកែវកំបោរក្រហមទុកឆីស្លាមួយដាក់បង្កប់ទៀត។

នៅពេលដែលពិធីរៀបចំបានគ្រប់សព្វ គឺនៅលើគ្រែពោរពេញទៅដោយបន្លែបង្ការនិង

ផលានុផល ដូចជា ចេក ដូង ក្រូចនិងមៀន គ្រាប់ពូជ ព្រមទាំងទឹកសមួយចានដែកធំផងដែរ។

ក្នុងទឹកនោះមានផ្ថិលមួយទុកជាស្រេច។ គ្រូភាបេះបោចផ្កាភ្ញីទម្លាក់ទៅក្នុងទឹកនោះ ហើយដកទឹកអប់មួយដបថ្មីពីហោប៉ៅអាវ មកបាញ់ដាក់ផង។

គ្រប់គ្នាមើលដឹងថា នេះគឺជាទឹកមន្តសម្រាប់ស្រោចឲ្យសីហា។

ប្រាកដណាស់ លោកអាចារ្យភ័ក្ត្របានចុះមកដល់និងស្រែកបញ្ជាឡើង៖

«តស់ដាស់អន្ទិតនេះចុះទៅក្រោម»

គាត់និយាយប្រាប់ដោយដៃកាន់ធូបមួយសំណុំធំនោះបន្តជានិច្ច។

ម្តាយសីហាបានដាស់កូនពីរបីដង ហើយកែមនិងបងជីដូនមួយគេចាប់ផ្តើមជួយគ្រាហ៍គេដែលសើងម៉ើងចុះទៅដី។

ពួកគេឲ្យសីហាអង្គុយនៅលើកៅអីជ័រមួយចំពីមុខគ្រែដោយគ្មានអ្នកណាអង្គុយទៀតនោះទេគ្រប់គ្នាឈរពីក្រោយខ្នង។

មានតែលោកអាចារ្យភ័ក្ត្រដែលកាន់ធូប ហើយចាប់ផ្តើមសូត្រធម៌ទៀត។ ចាស់ៗឈរជុំវិញនោះប្រណម្យសូត្រដូចគ្នានៅពីមុខគ្រែ។ អ្នកភូមិមកមើលច្រើនឡើងៗតែក៏គ្មានអ្នកណានិយាយអ្វី ឮសូរតែមាន់ទាំងពីរដែលចឹកស្រូវចុះឡើងយ៉ាងសប្បាយត្រេកអរ។

ពេលនោះ សូត្របានបន្តិច ពីបាលីដែលស្តាប់មិនដឹងអត្ថន័យ លោកអាចារ្យភ័ក្ត្របានស្រែកឡើងថា៖

«អញឲ្យមាន់ឯង អញឲ្យស្រូវឯង ឯងយកបន្លែឯអញយកមនុស្ស! ឯងយកផ្លែឈើឯងអញយកមនុស្ស អាឯងយកមាន់ អញនេះយកមនុស្ស អញយកតែមួយ ឯងយកទាំងអស់ចុះ! អញយកតែមនុស្ស អញយកគ្រប់គ្នា!»

គាត់និយាយបែបនេះដដែលជាដដែលបាន៧ចប់ រួចដើរចុះឡើងជាមួយនឹងបាលីសំស្រ្កិត ភាសាឥណ្ឌា ភាសាផ្សាជាច្រើនទៀត ស្តាប់មិនយល់ ប៉ុន្តែអ្នកមកពីទីក្រុងទាំងប៉ុន្មាននេះដឹងបានថា គាត់ជាអ្នកចេះអាគមបុរាណពិតប្រាកដណាស់ បើមើលតាមអាកប្បកិរិយាសង្រ្គោះរបស់គាត់។

អ៊ំភក្រ្តនេះមិនត្រឹមមិនបានទាមទារថ្លៃថ្នូរនៃការធ្វើសំណែនថែមទាំងឱ្យកូនទៅរបស់របរបានមកហើយ ក៏ហៅអ្នកភូមិមកជួយ ដូចជាពួកគេថ្មីកស្ទាត់ជំនាញចំពោះពិធីនេះ។

មិនបានប៉ុន្មានការសូត្រប្រោះព្រំនិងទាំងអស់បានបញ្ចប់ទៅរហូតដល់ចាស់ៗចាប់ផ្តើមដោះខ្សែមាន់ហើយព្រលែងចេញពាសវាលកាល។

ដែលគំនិតវណ្ណដូនិងម្តាយសីហាគិតថា គេនឹងសម្លាប់មាន់បូជាយញ្ញ គឺជារឿងគិតខុសទាំងស្រុង។

ប្រពៃណីស្រុកនេះគេមិនធ្វើនោះទេ។ រីឯពួកបន្លែបង្ការទាំងអស់នោះត្រូវបានអាចារ្យរៀបចំចេញអស់ហើយ ឮថាគេយកទៅបណ្តែតទឹក។

សីហាត្រូវបានគេដាក់ឲ្យទៅអង្គុយលើគ្រែឫស្សីម្នាក់ឯងទៅវិញដោយមានម្តាយនៅអង្គុយក្បែរឯបងជីឈរក្រោមដើមឈើ ក្បែរវណ្ណដូ។

គ្រូសុភ័ក្របានបង្គាប់ទៅកាន់ម្តាយរបស់សីហាខណៈពេលដែលធូបក្នុងដៃគាត់នៅសល់តែប្រហែលកន្លះដើមតែប៉ុណ្ណោះ ឱ្យម្តាយយកធូបទាំងសំណុំនៅសល់នោះទៅជ្រលក់បញ្ចប់ការឆេះនៅក្នុងទឹក។

ឮសូរឈឹបៗចេញផ្សែងក្រអូបពេញនោះហើយ ធូបដែលនៅសល់គាត់ឱ្យយកទៅដោតនៅគល់ដើមចំបក់មួយ។

គាត់បានប្រាប់ទៅម្តាយរបស់សីហាឲ្យស្រោចទឹកឲ្យកូន។

«អ្នកស្រោចទឹកឲ្យកូនហើយ ត្រូវសុំទារយកសុខសប្បាយមកវិញ សុំឲ្យកូនប្រុសបានភ្លឺស្វាង សូមឲ្យអំពើឧក្រិដ្ឋនានាដែលគ្រប់សន្ធប់លើអន្ទិតនេះចាកចេញឲ្យឆ្ងាយបង់ចាប់ពីពេលនេះវេលានេះដែរ!»

ម្ដាយសីហាប្រណមឡើងហើយនិយាយសារភាពថា ៖

«ខ្ញុំមិនដឹងទេ ថាត្រូវធ្វើយ៉ាងណាទេលោកបង!»

ឪពុកគ្រូនភាប្រាប់ទៀតថា៖

«អ្នកជាម្ដាយ ចូលអ្នកស្រោចទឹក ហើយបួងសួងវត្ថុសក្ដិសិទ្ធិទាំងអស់នៅទីនេះសុំតែសេចក្ដីសុខមកឲ្យកូនប្រុសនោះជាការស្រេច!»

ពេលនោះហើយដែលពូកែមល្មួចខ្សឹបប្រាប់វណ្ណដូថា យើងជាកូនប្រុសតែងត្រូវការម្ដាយស្រោចទឹកជាគ្រឿងសេរីក្បួនខ្មែរយើងតាំងពីបុរាណមក។ មុនពេលចេញទៅណាមកណា

បានត្រឹមតែជាយសារុងរបស់ម្ដាយយកមក ចងក្បាលឬក៏ទុកជាប់ខ្លួន ឬបានយកដានជើងម្ដាយឪពុកក្មេកតាមសម្រាប់ ថ្វាយបង្គំ ឬមួយក៏ឲ្យម្ដាយស្រោចទឹកគឺរួចជាស្រេចនូវបណ្ដាសាអាក្រក់ទាំងពួង។ យើងប្រាកដជាមានស្មារតីភ្លឺស្វាងមោះមុតនេះគឺជាជំនឿរបស់មេទ័ពនានាខ្មែរយើងតាំងពីសម័យដើមមកនៅក្នុងការចេញធ្វើសង្គ្រាមមិនដែលចេះខ្លបខ្លាចបាក់ស្បាតចំពោះសត្រូវណាឡើយ មិនខ្លាចទាំងមនុស្ស មិនខ្លាចទាំងទេវតា មិនខ្លាចទាំងសភាវៈផ្សេងផង។

រួចពិធីនោះកាលណា ក៏ថ្ងៃបាក់រសៀលល្មមមិនអាចត្រឡប់មកភ្នំពេញបានទាន់ទេ។ ដូច្នេះបានទេ លោកតាបានហៅពួកគេឲ្យស្នាក់នៅទីនេះ ប៉ុន្តែគ្រូភាបាននិយាយថាប្រពន្ធរបស់គាត់បានរៀបចំម្ហូបចំណីអាហារដូច្នេះគាត់នឹងអញ្ជើញក្រុមអ្នកភ្នំពេញឲ្យទៅស្នាក់នៅផ្ទះរបស់គាត់វិញ។

ម្ដាយរបស់សីហាបានរួសរាន់សុំឱ្យគ្រូនភាទូទាត់ថ្លៃសំណែន និងសាកសួររកទ្រនឹបដែរតែត្រូវគ្រូភ័ក្រ្ដប្រាប់ថា សុំត្រឹមទឹកមួយផ្តិល។ វណ្ណដូស្ដាប់មិនយល់ទេតែឃើញគ្រូឯមខ្សឹបទៅបងជីដូនមួយរបស់សីហា គេនោះក៏ខ្ចីម៉ូតូអ្នកភូមិជិះទៅទិញទឹកសុទ្ធនិងភេសជ្ជៈជាច្រើនយកមកជូនចំពោះលោកគ្រូភ័ក្រ្ដនិងចាស់ៗក្នុងវត្តថែមទាំងប្រគេនបច្ច័យខ្លះជួយដល់វត្តអារាមមួយនេះផងដែរ។

ព្រលប់នោះសីហាហូបបាយច្រើនធ្វើឲ្យម្ដាយគេត្រេកអរយ៉ាងខ្លាំង។ នៅផ្ទះគ្រូនភានេះដែរ ពេលបាយរួច អ៊ំកែមបានលាក្រដាសមួយ ដែលគាត់បានកត់ត្រាឡើងតាមបង្គាប់របស់គ្រូភក្ត្រ យកមកអានប្រាប់មកម្ដាយកូនទាំងពីរថា ៖

«ចៅសីហា លែងអីហើយ តទៅតមហូបគ្រឿងឆៅបីឆ្នាំ តមត្របែក តមចេកអំបូង តមក្រូចគ្រប់មុខ និងតមដំណើបខ្មៅ! ហាមមើលគេធ្វើសត្តឃាត ហាមហូបដុំឈាមអ្វីក្ដី! ពីនេះទៅចៅបានសុខសប្បាយហើយ!»

ជាបណ្ដើរៗ សីហាចាប់រួសរាយឡើងៗលែងមុខខ្មៅដូចកាលមកដំបូងហើយ។

គេបានមកអង្គុយជជែកលេងនិងស្ដាប់អ្នកភូមិទាំងញញឹមញញែម។

គ្រូនភាបានឆ្លៀតប្រាប់ម្ដាយសីហាថា ឲ្យកាន់តំណមឲ្យបានទៀងទាត់ ចំណែកគ្រូភ័ក្ត្រមិនបានមកទីនេះជាមួយពួកគេនោះទេ។

ឆ្លៀតពេលសីហានិងម្ដាយទៅសម្រាកឆ្ងាយបន្តិច បងប្រុសជីដូនមួយរបស់សីហាបានឆ្លៀតសួរដំណើរដើមទងនៃរឿងនេះ។ វណ្ណដូក៏នៅទីនោះ អង្គុយស្ដាប់គ្រូភានិយាយ ប្រាប់ច្បាស់ៗថា នេះគឺជាតំណាលអសុរកាយមួយ ដែលអ្នកភូមិចងចាំមកគ្រប់គ្នា។

គេជឿថាមានពិតមែនអ្នកភូមិជឿរឿងដែលថាមានក្មេងស្រីម្នាក់ជាទាសករមានចរិតមិនស្មោះត្រង់ត្រូវបានចៅហ្វាយ ដាក់ទោសទណ្ឌប៉ុន្តែដោយខ្លួនឯងជាទីស្អប់ខ្ពើមនៃអ្នកបម្រើដទៃទៀតនាងក៏ត្រូវបានគេលួចសម្លាប់។

នាងបានស្លាប់ទៅដោយមិនអស់ចិត្ត ហើយព្រលឹងបានវិលវល់មករុកគួនម្ចាស់ផ្ទះរហូតដល់មានអ្នកស្លាប់នៅក្នុងផ្ទះជាបន្តបន្ទាប់ ដូចជាអ្នកបម្រើដែលបានសម្លាប់នាង និងស្វាមីរបស់ម្ចាស់ផ្ទះ។

ក្រោយមកម្ចាស់ផ្ទះទ្រាំមិនបាន ក៏ដឹងហេតុភេទទាំងនេះនិង ជួលអាចារ្យដ៏ពូកែម្នាក់មកពីមកពីដែនដីឆ្ងាយឈ្មោះថាអាចារ្យដួង។

ពេលនោះហើយដែលវណ្ណដូវដឹងថា អាចារ្យដួងមានកូនសិស្សម្នាក់ឈ្មោះនាយមន្ត គឺជាជីតាទួត របស់អាចារ្យភ័ក្ត្រ។ កូនសិស្សអាចារ្យដួងម្នាក់នោះ គឺជាអ្នកឃើញហេតុការណ៍ផ្ទាល់កាលពីសម័យកាលប្រវត្តិកកើតដើមនៃព្រាយបិសាចចង្កៀងថ្ម និងការសន្ទប់ចម្លាក់មកទល់ឥឡូវ។

នេះបានន័យថា ត្រកូលគ្រូនភាមិនមែនជាអ្នកស្រុកនេះតាំងពីដើមរៀងមកទេ។ គាត់គឺជាអ្នកចំណូលថ្មី ដែលមុនពេលអាចារ្យដួងចាកចេញពីភូមិស្រុកនេះ គាត់បានអង្គុយភាវនាបីយប់បីថ្ងៃអំពីអនាគតនៃស្រីព្រាយនៅក្រោមចម្លាក់ ក្រោយមកគាត់ក៏បានបង្គាប់ឲ្យចៅមន្តដែលជាកូនសិស្សរបស់គាត់ បន្តរកប្រពន្ធកូនរស់នៅទីនេះថែរក្សាសុវត្ថិភាពអ្នកភូមិនិងផ្សារភ្ជាប់នូវមន្តអាគមដែលគាត់ចេះទាំងប៉ុន្មានផ្សព្វផ្សាយបន្តដល់ជំនាន់ក្រោយឱ្យចេះប្រាកដ ដើម្បីការពារមិនឲ្យព្រាយនេះអាចចេញមកធ្វើអ្វីៗតាមទំនើងចិត្តបានទៀត។

ទំនងដូចជាអាចារ្យដួងអាចភាវនាដឹងមុនថាច្រើនឆ្នាំក្រោយមក ស្រីព្រាយនេះអាចដាក់បណ្ដាសាថា ប្រសិនបើមានបុរសភេទណាមកប៉ះពាល់ចង្កៀងនេះដោយចិត្តស្រឡាញ់ស្ងប់ស្ងែង នាងនិងមានសមត្ថភាពក្នុងការតាមរកបុរសនោះទៅយាយី ធ្វើជាស្រីស្នេហ៍របស់មនុស្សប្រុសម្នាក់នោះ។

ពេលឮលោកគ្រូភានិយាយដល់ត្រឹមនេះ វណ្ណដូដូចជាហួសចិត្តយ៉ាងខ្លាំងព្រោះអីវណ្ណដូដូចជាគិតថា រឿងហេតុស៊ីសង្វាក់គ្នាទៅនឹងអ្វីដែល មិត្តភក្តិរបស់គេគឺសីហាបានជួបប្រទះ។

«ចុះម៉េចក៏លោកគ្រូមិនស្នើសុំឲ្យសាលាខេត្តបិទបាំងកុំឲ្យមានក្មេងប្រុសណាអាចមកប៉ះពាល់ចង្កៀងថ្មនេះបាន?»

«យើងមិនអាចយកអបិយជំនឿនិងពាក្យបណ្ដាសាយកមកនិយាយជាមួយអាជ្ញាធរឲ្យគេធ្វើតាមយើងនោះទេ! កន្លងមកមានអ្នកមកទស្សនាច្រើនដែរ! កាលពីប្រហែលជាប្រាំពីរឆ្នាំមុនធ្លាប់មានម្នាក់មានករណីដូចជាសីហាអ៊ីចឹង! ហើយខ្ញុំបាននិយាយជាមួយបងប្រធានមន្ទីរទេសចរណ៍ខេត្ត គាត់យល់ព្រមឲ្យខ្ញុំតែម្នាក់គត់ជាអ្នកនាំភ្ញៀវទាំងអស់មកមើលចង្កៀងនេះពេលណាខ្ញុំអវត្តមានគឺមិនអាចឲ្យមកមើលទីនេះបានទេ!»

ដូច្នេះហើយបានជាកាលពីថ្ងៃនោះ លោកគ្រូហាមសីហាមិនឲ្យប៉ះដែរ ប៉ុន្តែសីហាបានឆ្លោយប៉ះពាល់មុនទៅហើយ។

«ហើយនេះគឺជាមេរៀនសម្រាប់គ្រូដែរ! ថ្ងៃក្រោយគ្រូនិងប្រាប់គ្រប់គ្នាតាំងពីនៅលើឡានគឺមិនរង់ចាំដល់ពេលមកដល់ទីកន្លែងនោះទេ!»

ចេញមកផ្ទះវិញកាលណាវណ្ណដូវិញនៅតែលួចគិតក្នុងចិត្តថា សម្រាប់មនុស្សខ្លះដែលចង់ដឹងចង់យល់ឬមួយក៏ត្រូវរងពួករបស់មន្តអាគមស្រីព្រាយនៅខាងក្រោមនោះអន្ទងហៅ ប្រាកដ

ណាស់ ទោះបីថាមានការហាមឃាត់យ៉ាងណាក៏នៅតែចង់ប៉ះអង្គែលចង្កៀងថ្មដូចគ្នាដូច្នេះរឿងនេះប្រហែលជាមិនចប់ដោយងាយៗនោះឡើយ។

តំណាលអសុរកាយបានក្លាយទៅជារឿងថ្មីសម្រាប់វណ្ណដូសរសេរផ្សព្វផ្សាយ នៅពេលដែលត្រឡប់ទៅសាលា ទាំងមិនដឹងថានឹងមានអ្នកណាជឿឬមិនជឿទេ តែវណ្ណដូនៅតែចង់ធ្វើរឿងនេះ។ ចំណែកសីហាក៏បានរួមរស់សុខសាន្តជាមួយម្តាយដូចគ្រាមុន។

ឆ្នាំ២០២១

«ស្តាប់ណ៎ាទាំងអស់គ្នា! នេះគឺជាចម្លាក់ចង្កៀងដែលសល់តាំងពីសម័យកាលបារាំងមកម្ល៉េះ ហើយធ្លាប់មាន គេនិយាយដែរថា ដោយសារតែចម្លាក់នេះតែងតែអន្ទងចិត្តមនុស្សឲ្យចង់ស្ទាបអង្គែលប៉ុន្តែហើយគ្រប់អ្នកដែលបានស្ទាបអង្គែលទាំងអស់សុទ្ធតែមានបញ្ហាដូចជាត្រូវខ្មោចចូលនៅពេលត្រឡប់ទៅផ្ទះវិញ អ៊ីចឹងហើយបានជាយើងឃើញមានរបងនេះត្រូវបានគេសង់ឡើងតាំងពីប្រហែលជាសាមសិបឆ្នាំមុន!»

«ខ្មោចចូល?»

សុខធីនិងហាកានិយាយចំអកដោយងាកសម្លឹងទៅកាន់ ដេននីដែលជាមិត្តភក្តិស្រីៗរបស់នាង។ ភ្លាមនោះ ដេវីត ដើរមកក្បែរនារីទាំងពីរហើយនិយាយឡើងថា៖

«អូយ គិតម៉េចទៅដេន្នីនិងសុភី? ខ្ញុំបានឮមនុស្សស្រីម្នាក់ខ្សឹបឲ្យខ្ញុំចូលស្ទាបចង្កៀងនេះ គឺខ្ញុំមានអារម្មណ៍ថាចង្កៀងនេះមានក្លិនក្រអូបដូចជាខ្លួនមនុស្សស្រី ហើយមានសំឡេងខ្សឹបៗមកមើលទៅស្រើបស្រាលគួរឱ្យក្នុងចិត្តខ្ញុំនេះស្រៀវស្រើបដូចជាចង់លូកដៃទៅប៉ះម៉េចទេ!»

ដេន្នីឮហើយក៏ចំអក៖

«ទៅប៉ះទៅចឹង! បបួលហាកានិងសុធីផង! មើលទៅសុទ្ធតែត្រូវអន្ទងហើយដឹង? ញញឹមរហូតបីនាក់នេះ ចំមែន!»

សុខធីស្រែកមកវិញឱ្យស្រីៗ៖

«ស្មានថាខ្លាច?!»

ហាកាស្រែកដែរ៖

«ស្មានតែចម្រឹងប៉ុណ្ណឹងហាមឃាត់ខ្ញុំបានអី?»

«ប៉ះទៅ! ទៅប៉ះទៅ! អេសហាកា សុធី ដេវីតនេះមកនិយាយអ៊ីចឹងទៅកើត!» សុភីថាទាំងលើកសៀវភៅយកមកវ៉ៃខ្នងដេវីតធ្វើឲ្យដេវីតដែលកំពុងតែប្រឹងលេងកំប្លុកកំប្លែងជាមួយពួកនាង រត់ចាកចេញពីនារីៗតែទេសកាលអី គេរត់មិនបានប៉ុន្មានផងគេក៏ជំពប់ជើងភ្លាត់ស្លៀតជំហរដួលផ្ងាល ប៉ុន្តែមិនបានដួលរលេដល់ដីដោយដៃទាំងពីរទប់ជំហរទៅនឹងផ្ទាំងចម្លាក់ចង្កៀងថ្ម។

បរិយាកាសទៅជាស្ងាត់ច្រៀបព្រោះសិស្សគ្រប់គ្នាងាកមកមើលដេវីត ដែលប្រើបាតដៃទាំងពីរទ្រមាមដៃទាំងដប់រំលងពីចម្រឹង ច្រត់ទប់ខ្លួនគេនឹងចម្លាក់ហាមឃាត់។

ដៃគេលូកហួសរបងដែកដែលអាជ្ញាធរដាក់ការពារមិនឲ្យគ្រប់គ្នាប៉ះដល់ចង្កៀង ប៉ុន្តែហត្ថទាំងពីរដ៏វែងរបស់គេពិតជាបានប៉ះដល់ជញ្ជាំងនោះហួសទៅហើយ។

«វរហើយ វាស្ទាបរូបចម្លាក់ចង្កៀងពេញទំហឹងតែម្តង ដៃពីរទៀត អូ អាពួកម៉ាក់អើយ! ប៉ះស្អីលម៉េះ!»

ហាកានិងសុធីមិត្តរបស់គេសើចក្អាកក្អាយចង្អុលមុខដេវីតធ្វើឲ្យសាមីខ្លួនធ្វើមុខរាងអៀនប្រៀនក្រហមរងាល។ គ្រូសម្តស្សរត់មកដោយទឹកមុខស្លេក។

«ម៉េចចឹងប្អូន ដេវីត?»

ដេវីតហាក់មិនស្រួលក្នុងចិត្តដែរតែគេធ្វើពើសួរវិញថា៖

«ស្អីគេនៀក ដកដៃចេញពីចង្កៀងមិនរួចអន្ទងអីអន្ទងម៉េះនៀក?!»

«កុំនិយាយលេងសើចដេវីត!»

គ្រូសម្តស្សព្រមានហើយជួយទាញដើមដៃរបស់គេចេញ។ ដៃដេវីតដូចជាចង់ធំជាងប្រឡោះនៃចម្រឹងដែក រហូតដល់ពួកម៉ាក់របស់គេមកជួយទៀយទើបដករួច។

នៅលើឡានហាកាឆ្លៀតចំអកខ្សឹបខ្សៀវថា៖

«ចាំមើលទៅ! ឯងប៉ះជញ្ជាំងនោះហើយ យើងមិនដឹងទេ! ឯងបានសង្សារមកតាមហើយ!»

«អញស្រលាញ់ប្រុសទេវ៉ី!»

ដេវីតនិយាយចំអកវិញហើយកៀកកមិត្តមក សើចក្អាកក្អាយ ព្រមទាំងបន្តសែលហ៊ីជាមួយគ្នាយ៉ាងរីករាយ។

ម៉ោងដប់ពីរយប់នៅផ្ទះដេវីត....

តុកតុកតុកតុក ស្នូរកណ្ដឹងទ្វារលាន់ឡើង ដេវីតញីភ្នែកព្រោះគេកំពុងតែមើលទូរសព្ទរឿងខ្មោច មិនទាន់គេងលក់នៅឡើយ គេក្រោកប្រុងក្រោកចេញទៅបើកទ្វារ ស្រាប់តែ

កន្ទុយភ្នែកហាក់ឃើញមនុស្សណាម្នាក់ឈរក្បែរវេរ៉ង់ដាខាងមុខបន្ទប់ទទួលភ្ញៀវឲ្យខ្នងមកក្នុងហើយមានសក់វែងអន្លាយ។

រាងដូចជាម្ដាយរបស់គេ?

ចុះអ្នកណាមកគោះទ្វារបើម្ដាយមកដល់ហើយ ចំណែកបើគាត់មកមែនម៉េចក៏គាត់ចូលមកមិនឮសូរហើយទៅឈរម្នាក់ឯងបែនេះ?

ទម្លាប់រាល់ដងគាត់តែងមកអើតមើលកូនប្រុសសិនពេលមកដល់ផ្ទះ?

គេងាកមកចុចទូរសព្ទបិទហើយឈានទៅសម្លឹងម្ដងទៀត នៅតែឃើញម្ដាយឈរបែរខ្នង។

ប្រុងថានិយាយសួរមួយម៉ាត់ទៅកាន់ម្ដាយតែស្នូរចុចកណ្ដឹងរន្ថើនពេកក៏បែរទៅរកទ្វារមុន។

«អ្នកណា?»

គេសួរពីក្នុងផ្ទះ។

«ម៉ាក់! មាននរណាទៀត?»

បេះដូងដេវីតចង់គាំងតែដៃរបស់គេមិនស្ទៀមនោះទេ។

គេចុចបើកសោឱ្យ។

ម្ដាយចូលមកដល់ដោយទឹកមុខស្លេកហត់និងមានធុំក្លិនស្រាផង។

«ម៉ាក់រវល់ពេក ញ៉ាំអីនៅដេវីត!»

ដេវីតមិនតបតែគេចង់ងាកទៅវេរ៉ង់ដាសាជាថ្មី។ គេមិនឃើញមានអ្នកណានៅទីនោះទៀតទេ។

ដេវីតគិតម្នាក់ឯងឡើង៖

«ខ្ញុំមើលរឿងខ្មោចតាស៎ មិនមែនផឹកស្រាដូចម្ដាយខ្ញុំឯណា? ហេតុអីបានជាស្រវាំងភ្នែក!»

«កូនអ្នំា មួយរយៈនេះម៉ាក់មានអារម្មណ៍ថា មានបញ្ហាកើតឡើងច្រើនដងហើយ ម៉ាក់យល់សប្តិប្លែកៗ យល់ថាគួរតែនិមន្តព្រះសង្ឃមកផ្ទះយើងម្តងឬក៏យ៉ាងម៉េច?!»

ដេវីតអេះក្បាលតបវិញ៖

«មានបញ្ហាគួរតែដោះបញ្ហា មិនមែននិមន្តព្រះសង្ឃមកផ្ទះទេម៉ាក់ កំពុងកូវីដផង! អូខេ មានមធ្យោបាយ! ខ្ញុំមានសៀវភៅ Problem Solving ខ្ចីអានដែរទេ? រកឱ្យបាន!»

គេថាហាក់ចំអកឲ្យម្តាយហើយក៏ដើរត្រុយចូលក្នុងបន្ទប់ខ្លួនបិទទ្វារដេកវិញ។ ភ្លាមនោះសម្រែកមួយលាន់ឡើងខ្ទរខ្ទារពីក្នុងបន្ទប់របស់ដេវីដធ្វើម្តាយគេនៅក្បែរទូស្បែកជើង រត់ឆ្ពោះមកក្បែរទ្វារ គោះទម្លាយយ៉ាងណាក៏មិនរបើក។

៤ថ្ងៃក្រោយមកឡើងនៅមន្ទីរពេទ្យចិត្តសាស្ត្រ .....

«ក្មួយមើលខ្ញុំឲ្យចំ! ហើយរៀបរាប់នូវអ្វីដែលក្មួយបានជួបនូវកាលពីយប់មិញ!»

«ខ្ញុំបានប្រាប់លោកគ្រូពេទ្យពីរដង! ហើយគឺ យប់មួយខ្ញុំស្រាប់តែឃើញមនុស្សស្រីម្នាក់សក់វែងកំពុងឈរបែរខ្នងច្បាស់នឹងភ្នែកនៅវេរ៉ង់ដា! ក្រោយមកទៀតខ្ញុំបើកទ្វារបន្ទប់ចូលទៅឃើញមនុស្សស្រីម្នាក់ទៀតកំពុងអង្គុយលើគ្រែរបស់ខ្ញុំពេលនោះខ្ញុំស្រែកហើយសន្លប់បាត់ ម៉ាក់របស់ខ្ញុំមានសោក៏បើកទ្វារចូលមិនបាននោះទេ ក្រោយក្រោយមកទៀត! ខ្ញុំតែងតែឃើញមនុស្សស្រីដដែលៗនោះពេលខ្ញុំបើកទូរស័ព្ទឬមួយក៏ខ្ញុំចូលជណ្តើរយន្ត! ឥឡូវនេះរៀនលែងចង់កើតហើយ! ម្តាយខ្ញុំឱ្យរើខ្ញុំចេញមក សម្រាកនៅផ្ទះលោកតាលោកយាយខ្ញុំមួយរយៈស្តាប់គាត់សូត្រធម៌! ខ្ញុំមិនសូវឃើញមនុស្សស្រីម្នាក់នោះពិតមែនប៉ុន្តែខ្ញុំមានអារម្មណ៍ថាអ្នក អ្នកណាម្នាក់បានមកតាមខ្ញុំរហូត! សូម្បីតែទីនេះ .....ពេលនេះ....!»

តើអ្នកយល់យ៉ាងណាដែរចំពោះប្រលោមលោកតំណាលអសុកាយមួយនេះ!